# សុន្ទរកថា
# ឯកឧត្តម សក់ សេដ្ឋា រដ្ឋលេខាធិការក្រសួងមហាផ្ទៃ
# និងជាប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប
# ក្នុងពិធីបិទសិក្ខាសាលាពិគ្រោះយោបល់ស្តីពី
# កិច្ចដំណើរការផ្ទេរមុខងារទៅក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ

ថ្ងៃទី ០៧ ខែវិច្ឆិកា ឆ្នាំ ២០១១

**សណ្ឋាគារ ភ្នំពេញ**

**ឯកឧត្តម លោកជំទាវ លោក លោកស្រី!**

ថ្ងៃនេះខ្ញុំមានកិត្តិយស និងមានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង ដែលបានចូលរួមក្នុងពិធីបិទសិក្ខាសាលាពិគ្រោះយោបល់ ស្តីពីកិច្ចដំណើរការផ្ទេរមុខងារ និងធនធានទៅរដ្ឋបាលថ្នាក់ក្រោមជាតិដ៏មានសារសំខាន់នាថ្ងៃនេះ។ ជាមួយគ្នានេះដែរ ខ្ញុំក៏មានសេចក្តីរីករាយ ដែលបានស្តាប់នូវរបាយការណ៍នៃអង្គសិក្ខាសាលាដែលបានបញ្ជាក់ថា អង្គសិក្ខាសាលាបានប្រព្រឹត្តទៅដោយរលូន និងមានការចូលរួមយ៉ាងផុលផុសពីសំណាក់សមាជិក សមាជិកានៃអង្គសិក្ខាសាលា និងព្រមទាំងបានទទួលលទ្ធផលជាផ្លែផ្កាតាមគោលបំណងដែលបានគ្រោងទុក។

ឆ្លៀតក្នុងឱកាសនេះ ក្នុងនាមលេខាធិការដ្ឋាន គ.ជ.អ.ប ខ្ញុំសូមថ្លែងអំណរគុណដល់ក្រុមការងារលេខាធិការដ្ឋាន គ.ជ.អ.ប ដែលបានសហការជាមួយក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធនានាក្នុងការរៀបចំ និងសម្របសម្រួលអង្គសិក្ខាសាលានេះឲ្យបានទទួលជោគជ័យ និងជាពិសេសខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះឯកឧត្តម លោកជំទាវ អស់លោក លោកស្រីទាំងអស់ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ដើម្បីចូលរួមផ្តល់ធាតុចូលក្នុងសិក្ខាសាលារយៈពេលមួយថ្ងៃនេះ។ រាល់មតិ យោបល់ និងអនុសាសន៍នានាដែលទទួលបានក្នុងអង្គសិក្ខាសាលានាថ្ងៃនេះ ពិតជាមានសារសំខាន់ សម្រាប់ធ្វើជាមូលដ្ឋានក្នុងការរៀបចំលិខិតបទដ្ឋានគតិយុត្ត និងសេចក្តីណែនាំបច្ចេកទេសនានា ដើម្បីគាំទ្រដល់ការអនុវត្តកិច្ចដំណើរការផ្ទេរមុខងារ និងធនធនទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយរលូន និងមានប្រសិទ្ធភាពខ្ពស់។

ការផ្ទេរមុខងារ និងធនធានទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ជាសមាសធាតុស្នូលមួយនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ ការផ្ទេរមុខងារ និងធនធានទៅរដ្ឋបាលថ្នាក់ក្រោមជាតិមានគោលបំណងដើម្បីជំរុញឲ្យបរិមាណ គុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈជូន

ប្រជាពលរដ្ឋនៅមូលដ្ឋានមានលក្ខណៈកាន់តែល្អប្រសើរឡើង។ ក៏ប៉ុន្តែ ការផ្ទេរមុខងារ និងធនធានទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ក៏នឹងជះឥទ្ធិពលយ៉ាងខ្លាំងទៅលើកិច្ចដំណើរការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិផងដែរ។ អាស្រ័យហេតុនេះ ក្នុងកិច្ចដំណើរការរៀបចំផ្ទេរមុខងារ និងធនធាន គឺតម្រូវឲ្យមានការប្រមូលព័ត៌មានឲ្យបានជាក់លាក់ ធ្វើការវិភាគឲ្យបានស៊ីជម្រៅ និងហ្មត់ចត់ទៅតាមវិស័យ និងមុខងារនានាដែលកំពុងត្រូវបានអនុវត្តជាក់ស្តែងក្រោមការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ននៅថ្នាក់ជាតិ ព្រមទាំងក៏ត្រូវធ្វើការពិនិត្យ និងវិភាគផងដែរអំពីស្ថានភាព និងតម្រូវការជាក់ស្តែងផ្សេងៗគ្នានៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។ ជាមួយគ្នានេះដែរ ការផ្ទេរមុខងារ និងធនធានក៏ត្រូវធ្វើឡើងឲ្យស្របជាមួយនឹងការរៀបចំបង្កើតរចនាសម្ព័ន្ធគ្រប់គ្រង ប្រព័ន្ធកសាងផែនការ ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ និងប្រព័ន្ធបុគ្គលិករបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

មកដល់ពេលនេះ ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ (រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ត្រូវបានបង្កើត និងចូលកាន់មុខតំណែងរបស់ខ្លួនអស់រយៈពេលជាងពីរឆ្នាំមកហើយ។ រចនាសម្ព័ន្ធថ្មីនៃរដ្ឋបាលថ្នាក់ក្រោមជាតិទាំងនេះក៏ត្រូវបានរៀបចំបង្កើត មន្ត្រីនៃរដ្ឋបាលទាំងនេះក៏ត្រូវបានរៀបចំឡើងវិញ ប្រព័ន្ធកសាងផែនការអភិវឌ្ឍន៍ក៏ត្រូវបានបង្កើត និងដាក់ឲ្យអនុវត្ត ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំដែលជាមូលដ្ឋានគ្រឹះសម្រាប់អភិវឌ្ឍន៍មូលដ្ឋាន ក្នុងន័យឆ្លើយតបទៅនឹងតម្រូវការអាទិភាពរបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ក៏ត្រូវបានអនុម័តដោយក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិទាំងនោះរួចរាល់ផងដែរ។ ស្របពេលជាមួយគ្នានេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយសហការជាមួយក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាន គ.ជ.អ.ប កំពុងដុតដៃដុតជើងក្នុងការរៀបចំបង្កើតនូវប្រព័ន្ធផ្ទេរមូលនិធិ និងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់រដ្ឋបាលក្រុង ស្រុក ដើម្បីឲ្យរដ្ឋបាលថ្នាក់នេះមានធាធាន និងលទ្ធភាពសម្រាប់អនុវត្តផែនការអភិវឌ្ឍន៍របស់ខ្លួនក្នុងពេលឆាប់ៗខាងមុខនេះ។

ក្នុងខណៈដែលរចនាសម្ព័ន្ធ និងប្រព័ន្ធសំខាន់ៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ និងដាក់ឲ្យអនុវត្តជាបណ្តើរៗរួចហើយនោះ នេះជាពេលវេលាដ៏សមស្របមួយ ដែលយើងត្រូវចាប់ផ្តើមគិតគូរអំពីការផ្ទេរមុខងារសំខាន់ៗ និងធនធានឲ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិទាំងនោះ កាន់តែមានលទ្ធភាពគ្រប់គ្រាន់ក្នុងការរៀបចំ និងគ្រប់គ្រងការផ្តល់សេវានានាដែលខ្លួនអាចធ្វើបានប្រកបដោយប្រសិទ្ធភាព ជូនប្រជាពលរដ្ឋ តាមតម្រូវការដែលបានកំណត់នៅក្នុងផែនការអភិវឌ្ឍន៍របស់ខ្លួន ក្រោមការទទួលខុសត្រូវយ៉ាងពេញលេញ និងមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ជាការពិតណាស់ កិច្ចដំណើរការផ្ទេរមុខងារ និងធនធាន គឺជាកិច្ចការដ៏សាំញ៉ាំ និងរសើប តែជាកិច្ចការដែលយើងទាំងអស់គ្នាចាំបាច់ត្រូវតែអនុវត្ត ដោយមានការតាំងចិត្ត និងការសម្របសម្រួលជាមួយយុទ្ធសាស្ត្រតាមវិស័យនានាសម្រាប់ការលើកកម្ពស់ការផ្តល់សេវាសាធារណៈ។ ដូចឯកឧត្តម

**ព្រុំ សុខា** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាប្រធានអនុគណៈកម្មាធិការមុខងារ និងធនធាននៃ គ.ជ.អ.ប បានគូសបញ្ជាក់នៅក្នុងពិធីបើកអង្គសិក្ខាសាលានាពេលព្រឹកមិញនេះថា យើងនឹងបំពេញការងារនេះដោយប្រុងប្រយ័ត្ន និងដោយផ្អែកលើស្ថានភាពជាក់ស្តែងនៃសង្គម សេដ្ឋកិច្ច និងសមត្ថភាពធនធានមនុស្សរបស់យើង ជាមួយការរៀនសូត្របទពិសោធន៍ពីប្រទេសផ្សេងៗទៀត ទាំងនៅក្នុង និងនៅក្រៅតំបន់ ដើម្បីបង្ការកុំឲ្យមានការខុសឆ្គង និងត្រៀមលក្ខណៈបង្ការជាមុននូវបញ្ហាប្រឈម និងការគ្រប់គ្រងហានិភ័យនានា ដែលអាចលេចចេញពីដំណើរការផ្ទេរមុខងារ និងធនធាននេះឲ្យស្ថិតនៅក្នុងកម្រិតមួយដែលអាចគ្រប់គ្រង និងដោះស្រាយបាន។

សិក្ខាសាលានាថ្ងៃនេះ គឺជាការជួបជុំគ្នាជាលើកដំបូងរវាងក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធនានា ដើម្បីពិគ្រោះពិភាក្សា ប្រមូលមតិយោបល់ និងផ្តល់អនុសាសន៍លើគោលការណ៍ នីតិវិធី និងជំហាននានានៃកិច្ចដំណើរការផ្ទេរមុខងារ និងធនធានទៅរដ្ឋបាលថ្នាក់ក្រោមជាតិក៏ពិតមែន ក៏ប៉ុន្តែ ក្រោមក្របខណ្ឌនៃការអនុវត្ត **ជអ៣** លេខាធិការដ្ឋាន គ.ជ.អ.ប ក៏បានសម្របសម្រួលមួយដៃគូអភិវឌ្ឍន៍សំខាន់ៗ ក្នុងការសហការ និងផ្តល់ការគាំទ្រដល់ក្រសួង ស្ថាប័ននៃវិស័យអាទិភាពមួយចំនួន ដើម្បីពិភាក្សា និងចាប់ផ្តើមកិច្ចដំណើរការនៃការពិនិត្យមើលឡើងវិញនូវមុខងារ និងធនធានរបស់ខ្លួន ដែលនឹងត្រូវផ្ទេរទៅរដ្ឋបាលថ្នាក់ក្រោមជាតិជាបណ្តើរៗផងដែរ។ ក្នុងនាមលេខាធិការដ្ឋាន គ.ជ.អ.ប ខ្ញុំសូមថ្លែងអំណរគុណ និងកោតសរសើរដល់ក្រសួង ស្ថាប័នទាំងនេះចំពោះការឈានមុខលើកិច្ចការនេះ និងសូមលើកទឹកចិត្តឲ្យមានការសហការគ្នាជាបន្តទៀត។

*ពាក់ព័ន្ធនឹងបញ្ហាមួយចំនួនដែលបានលើកឡើងដោយក្រុមពិភាក្សានៃអង្គសិក្ខាសាលា ខ្ញុំសូមធ្វើការស្រាយបំភ្លឺបន្ថែមដូចតទៅ ....*

ជាកិច្ចបញ្ចប់ និងជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះឯកឧត្តម លោកជំទាវ អស់លោក លោកស្រីទាំងអស់ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ដើម្បីចូលរួមក្នុងអង្គសិក្ខាសាលារយៈពេលមួយថ្ងៃនេះ និងការចូលរួមចំណែកគាំទ្រដល់កិច្ចដំណើរការនៃកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

ខ្ញុំសូមជូនពរឯកឧត្តម លោកជំទាវ អស់លោក លោកស្រីទាំងអស់ទទួលបាននូវពុទ្ធពរទាំងបួនប្រការគឺ អាយុវណ្ណៈ សុខៈ ពលៈកុំបីឃ្លាងឃ្លាតឡើយ និង **សូមប្រកាសបិទជាផ្លូវការនូវសិក្ខាសាលាពិគ្រោះយោបល់ ស្តីពីកិច្ចដំណើរការផ្ទេរមុខងារ និងធនធានទៅរដ្ឋបាលថ្នាក់ក្រោមជាតិ** ពីពេលនេះតទៅ។

**សូមអរគុណ**